# 3.វិធីទទួលបានការថែទាំ

## ការថែទាំដោយមានការគិតគូរ

### សេវាដែលយល់ព្រមដោយអនីតិជន

ប្រសិនបើអ្នកមានអាយុក្រោម 18 ឆ្នាំ អ្នកមិនមិនចាំបាច់មានការអនុញ្ញាតពីឪពុកម្ដាយ ឬអាណាព្យាបាលដើម្បីទទួលបានសេវាថែទាំសុខភាពមួយចំនួននោះទេ ហើយអ្នកអាចទទួលបានសេវាទាំងនោះដោយសម្ងាត់ ដែលមានន័យថាឪពុកម្ដាយ ឬអាណាព្យាបាលរបស់អ្នកនឹងមិនត្រូវបានជូនដំណឹង ឬទាក់ទងឡើយប្រសិនបើអ្នកទទួលបានសេវាទាំងនេះដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សររបស់អ្នក។ សេវាទាំងនេះត្រូវបានហៅថា សេវាដែលយល់ព្រមដោយអនីតិជន។

អ្នកអាចទទួលបានសេវាកម្មខាងក្រោមនេះ ក្រោម **អាយុ 12 ឆ្នាំ**៖

- សេវាជំនួយជនរងគ្រោះដោយអំពើរំលោភផ្លូវភេទ
- សេវាទាក់ទងនឹងគភ៌ និងការមានផ្ទៃពោះ
- សេវារៀបចំផែនការគ្រួសារ ដូចជាសេវាពន្យារកំណើត (ឧ. ការគ្រប់គ្រងកំណើត)

បន្ថែមទៅនឹងសេវាដែលបានរាយខាងលើ អ្នកក៏អាចទទួលបានសេវាខាងក្រោមនៅ **អាយុចាប់ពី 12 ឆ្នាំឡើងទៅ** ផងដែរ៖

- ការប្រឹក្សាយោបល់ឬការព្យាបាលសុខភាពផ្លូវចិត្តរបស់អ្នកជំងឺមិនសម្រាកពេទ្យ។ ការណ៍នេះនឹងអាស្រ័យលើភាពចាស់ទុំ និងសមត្ថភាពរបស់អ្នកក្នុងការចូលរួមថែទាំសុខភាពរបស់អ្នក ដូចដែលបានកំណត់ដោយបុគ្គលដែលមានជំនាញវិជ្ជាជីវៈ

- ការចម្លងមេរោគ ជំងឺឆ្លង ឬការធ្វើរោគវិនិច្ឆ័យនិងការព្យាបាលជំងឺឆ្លង រួមទាំងមេរោគហ៊ីវ/ជំងឺអេដស៍
- ការការពារ ការធ្វើតេស្ត រោគវិនិច្ឆ័យជំងឺឆ្លងតាមការរួមភេទ (STI) និងការព្យាបាលជំងឺឆ្លងតាមការរួមភេទ (STI) ដូចជា រោគស្វាយ ប្រមេះទឹកបាយ ជំងឺឆ្លងទៅមនុស្សតាមរយៈសត្វល្អិត (Chlamydia) និង រោគឆ្លងតាមផ្លូវភេទដែលបង្កើតជាពងទឹកនៅតំបន់ប្រដាប់ភេទ (Herpes simplex)
- សេវាជំនួយជនរងគ្រោះដោយអំពើហិង្សាពីដៃគូជិតស្និទ្ធ
- ការព្យាបាលជំងឺដែលបណ្ដាលមកពីការប្រើសារធាតុញៀន (SUD) សម្រាប់ការសេពគ្រឿងញៀន និងគ្រឿងស្រវឹង រួមទាំងការពិនិត្យ វាយតម្លៃ កិច្ចអន្តរាគមន៍ និងសេវាបញ្ជូនបន្ត

អ្នកអាចទទួលបានសេវាដែលយល់ព្រមដោយអនីតិជនពីអ្នកផ្ដល់សេវា Medi-Cal ឬគ្លីនិកណាមួយ។ អ្នកផ្ដល់សេវាមិនចាំបាច់ស្ថិតនៅក្នុងបណ្ដាញថែទាំសុខភាព Molina Healthcare ឡើយ។ អ្នកមិនចាំបាច់ត្រូវការការបញ្ជូនបន្តពីអ្នកផ្ដល់សេវាថែទាំបឋម (PCP) របស់អ្នក ឬការយល់ព្រមជាមុនទេ (ការអនុញ្ញាតជាមុន)។

ប្រសិនបើអ្នកប្រើប្រាស់អ្នកផ្ដល់សេវាក្រៅបណ្ដាញសម្រាប់សេវាកម្ម **ដែលមិន**ទាក់ទងនឹងសេវាដែលយល់ព្រមដោយអនីតិជននោះ សេវាទាំងនោះប្រហែលជាមិនត្រូវបានរ៉ាប់រងឡើយ។

ដើម្បីស្វែងរកអ្នកផ្ដល់សេវា Medi-Cal នៅខាងក្រៅបណ្ដាញ Molina Healthcare Medi-Cal សម្រាប់សេវាដែលយល់ព្រមដោយអនីតិជន ឬដើម្បីសុំជំនួយក្នុងការដឹកជញ្ជូនដើម្បីទៅជួបអ្នកផ្ដល់សេវា សូមទូរសព្ទទៅផ្នែកបម្រើសេវាសមាជិក Molina Healthcare តាមរយៈលេខ 1-888-665-4621។

សម្រាប់ព័ត៌មានបន្ថែមអំពីសេវាពន្យារកំណើត សូមអាន “សេវាបង្ការ និងសុខុមាលភាព និងការគ្រប់គ្រងជំងឺរ៉ាំរ៉ៃ” នៅក្នុងជំពូកទី 4 នៃសៀវភៅណែនាំនេះ។

Molina Healthcare មិនរ៉ាប់រងសេវាដែលយល់ព្រមដោយអនីតិជន ដែលជាសេវាកម្មសុខភាពផ្លូវចិត្តពិសេស (SMHS) ឬសេវា SUD ភាគច្រើននោះទេ។

ខោនធីដែលអ្នករស់នៅជាអ្នករ៉ាប់រងសេវាកម្មទាំងនេះ។ ដើម្បីស្វែងយល់បន្ថែម រួមទាំងរបៀបចូលប្រើសេវាកម្មទាំងនេះ សូមអាន “សេវាកម្មសុខភាពផ្លូវចិត្តពិសេស (SMHS)” និង “សេវាព្យាបាលជំងឺដែលបណ្តាលមកពីការប្រើសារធាតុញៀន (SUD)” នៅក្នុងជំពូកទី 4 នៃសៀវភៅណែនាំនេះ។ ដើម្បីស្វែងយល់បន្ថែម សូមហៅទូរសព្ទទៅលេខ 1-888-665-4621 ជម្រើសទី 1។

ចំពោះបញ្ជីលេខទូរសព្ទឥតគិតថ្លៃរបស់ខោនធីទាំងអស់ សម្រាប់ SMHS សូមចូលទៅកាន់៖ http://www.dhcs.ca.gov/individuals/Pages/MHPContactList.aspx

ចំពោះបញ្ជីលេខទូរសព្ទឥតគិតថ្លៃរបស់ខោនធីទាំងអស់ សម្រាប់សេវាព្យាបាល SUD សូមចូលទៅកាន់៖ https://www.dhcs.ca.gov/individuals/Pages/SUD_County_Access_Lines.aspx។

អនីតិជនអាចពិភាក្សាជាមួយអ្នកតំណាងជាលក្ខណៈឯកជនអំពីកង្វល់សុខភាពរបស់ខ្លួន ដោយហៅទូរសព្ទទៅខ្សែគិលានុបដ្ឋាក 24/7 តាមរយៈលេខ 1-888-275-8750 (ភាសាអង់គ្លេស) ឬ 1-866-648-3537 (ភាសាអេស្ប៉ាញ)។

អ្នកអាចស្នើសុំឱ្យទទួលបានព័ត៌មានឯកជនអំពីសេវាវេជ្ជសាស្ត្ររបស់អ្នកជាទម្រង់ ឬរបៀបជាក់លាក់មួយ ប្រសិនបើមាន។ អ្នកអាចឱ្យគេផ្ញើវាទៅអ្នកនៅទីតាំងផ្សេងបាន។ ដើម្បីស្វែងយល់បន្ថែមអំពីរបៀបស្នើសុំទំនាក់ទំនងសម្ងាត់អំពីសេវាដែលមានការគិតគូរ សូមអាន “សេចក្តីជូនដំណឹងអំពីការប្រតិបត្តិឯកជនភាព” នៅក្នុងជំពូកទី 7 នៃសៀវភៅណែនាំនេះ។